រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៤

# អនុក្រឹត្យលេខ ២៥ អនក្រ

## ស្តីពីការកិច្ចនិងរចនាសម្ព័ន្ធចលនានៃកងរាជអាវុធហត្ថ

* * *

## រាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញក្រឹត្យ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងសហអគ្គមេបញ្ជាការ នៃកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា
- បានឃើញក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតអគ្គសេនាធិការដ្ឋាន នៃកងទ័ពជាតិកម្ពុជា
- បានឃើញយោបល់របស់ទីប្រឹក្សាខាងកិច្ចការពារជាតិនិងក្រុមប្រឹក្សាអ្នកច្បាប់អមនាយករដ្ឋមន្ត្រី

## សំរេច

**មាត្រា ១ :** កងរាជអាវុធហត្ថ ដែលឋិតនៅក្រោមការគ្រប់គ្រងរបស់អគ្គសេនាធិការកងយោធពលខេមរភូមិន្ទនោះ ត្រូវឋិតនៅក្រោមបញ្ជាការរបស់នាយករដ្ឋមន្ត្រី ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រី ជាអ្នកកំណត់គោលនយោបាយទូទៅ ។

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាអ្នកទទួលខុសត្រូវលើផ្នែករដ្ឋបាលទូទៅ និង ជាអ្នកផ្តល់សំភារៈ និង ថវិកាសំរាប់ផ្គត់ផ្គង់កងរាជអាវុធហត្ថ តាមរយៈអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ។

**មាត្រា ៣ :** កងរាជអាវុធហត្ថ ជាផ្នែកមួយរបស់កងយោធពលខេមរភូមិន្ទ ដែលមានបេសកកម្មក្នុងកិច្ចអនុវត្តច្បាប់ ។ កងរាជអាវុធហត្ថមានសកម្មភាពផ្តួចផ្តើម ដែលមានឧបនិស្ស័យ ជាអន្តរក្រសួង សមត្ថកិច្ចកងរាជអាវុធហត្ថ ត្រូវអនុវត្តពេញផ្ទៃប្រទេសទាំងមូលទៅលើពលរដ្ឋស៊ីវិល ព្រមទាំងទៅលើយោធាក្នុងជួរកងទ័ពផង ។

មាត្រា ៤ : កងរាជអាវុធហត្ថមានភារកិច្ច ÷

ក- រ៉ាប់រងសកម្មភាពខាងប៉ូលីសរដ្ឋបាល :

- រក្សាសុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈទូទៅ
- រ៉ាប់រងអោយមានការគោរពច្បាប់ និង បទបញ្ញាទាំងឡាយ
- ផ្តល់ពត៌មាន និង ជួយសង្គ្រោះពលរដ្ឋស៊ីវិល ។

ក្នុងករណី នៃការអនុវត្តន៏ភារកិច្ចនេះ កងរាជអាវុធហត្ថ អាចនឹងទទួលបញ្ជា ពីសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អាជ្ញាធររដ្ឋបាលមានសមត្ថកិច្ច ។

ខ- រ៉ាប់រងសកម្មភាពខាងប៉ូលីសតុលាការ :

- ពិនិត្យកត់ត្រានូវឧក្រិដ្ឋកម្ម និង ទោសកម្ម
- ធ្វើកំណត់ហេតុអំពីបទល្មើស
- ប្រមូលផ្តុំភ័ស្តុតាងផ្សេងៗ
- ស្រាវជ្រាវរករកអ្នកប្រព្រឹត្តបទល្មើស ដើម្បីបញ្ជូនខ្លួនទៅតុលាការ តាមដីកាតុលាការ
- ទទួលបន្ទុកអនុវត្ត តាមដីកាផ្ទេរអំណាចពីចៅក្រមស៊ើបសួរ ។

ក្នុងករណីអនុវត្តភារកិច្ចនេះ កងរាជអាវុធហត្ថអាចនឹងទទួលបទបញ្ជាពីរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ អង្គការអយ្យការ និង អាជ្ញាធរ តុលាការមានសមត្ថកិច្ច ។

គ- បំពេញបេសកកម្ម ដែលមានលក្ខណៈពិសេសខាងយោធា :

- ទទួលបន្ទុករក្សាសុវត្ថិភាព និង បំពេញតួនាទីជាកងកិត្តិយសជាប្រយោជន៏ដល់ស្ថាប័ន
- ការពារទីតាំងយោធា
- កិច្ចការប៉ូលីសយោធានៅក្នុង ឬ ក្រៅទីតាំងកងទ័ព ។

ក្នុងករណីអនុវត្តភារកិច្ចនេះ កងរាជអាវុធហត្ថអាចនឹងទទួលបញ្ជាពីសហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ និង អាជ្ញាធរយោធា មានសមត្ថកិច្ច ។

ឃ- ផ្តល់កំលាំងទៅជួយក្រសួងនានា ដែលបានស្នើសុំតាមសេចក្តីត្រូវការជាចាំបាច់ ។

មាត្រា ៥ : កងរាជអាវុធហត្ថអាចនឹងទទួលបេសកកម្មផ្នែកប៉ូលីស ពិសេសបន្ថែមដោយអនុលោមតាមអនុក្រឹត្យក្នុងបច្ឆាកាល ។

**មាត្រា ៦ :** រចនាសម្ព័ន្ធទូទៅរបស់កងរាជអាវុធហត្ថមាន :

- អគ្គិការដ្ឋានកងរាជអាវុធហត្ថ
- នាយកដ្ឋានកងរាជអាវុធហត្ថ

**មាត្រា ៧ : អធិការដ្ឋានកងរាជអាវុធហត្ថ**

អធិការកងរាជអាវុធហត្ថមានភារកិច្ចបំពេញបេសកកម្មត្រួតពិនិត្យ សិក្សា និង ផ្តល់ព័ត៌មាន ។

អធិការកងរាជអាវុធហត្ថ ត្រូវឋិតនៅក្រោមបញ្ជានាយករដ្ឋមន្ត្រីផ្ទាល់ដែលជាអ្នកកំណត់បេសកកម្ម ។

អធិការកងរាជអាវុធហត្ថ ជាទីប្រឹក្សាអធិទ្ធេយ៍របស់នាយករដ្ឋមន្ត្រី ។ ក្នុងករណីនេះ អធិការកងរាជអាវុធហត្ថ តម្រូវផ្តល់យោបល់ដល់នាយករដ្ឋមន្ត្រី នូវគ្រប់គំរោងស្តីពីអនាគតផ្នែករចនាសម្ព័ន្ធ និង មុខងាររបស់កងរាជអាវុធហត្ថ ។ អធិការកងរាជអាវុធហត្ថតោងតែតាមពិនិត្យមើលដោយផ្ទាល់ នូវកិច្ចប្រតិបត្តិការងារ និង ការប្រើប្រាស់បុគ្គលិកកងរាជអាវុធហត្ថអោយសមស្របតាមក្បួនច្បាប់ ។

**មាត្រា ៨ : នាយកដ្ឋានកងរាជអាវុធហត្ថ**

នាយកដ្ឋានកងរាជអាវុធហត្ថ ដឹកនាំដោយនាយកមួយរូប អាចជានាយទាហានថ្នាក់ឧត្តមសេនីយ៍ ឬ បុគ្គលិក ស៊ីវិលជាន់ខ្ពស់ មានភារកិច្ច :

- ចងក្រងបទបញ្ញត្តិការងារទូទៅ និង តាមពិនិត្យការអនុវត្តដោយមានទំនាក់ទំនងជាមួយក្រសួងពាក់ព័ន្ធ ដូចជាក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និង ក្រសួងយុត្តិធម៌ជាដើម ។
- ផ្តល់ព័ត៌មានដល់នាយករដ្ឋមន្ត្រីអំពីមធ្យោបាយគ្រប់យ៉ាងដែលមានភាពចាំបាច់ការងារបាន
- ដោះស្រាយកែសំរួលចំពោះបញ្ហាទាក់ទង ក្នុងការរៀបចំផ្នែករដ្ឋបាល និង ដំណើរការប្រព្រឹត្តិទៅរបស់កងរាជអាវុធហត្ថ ។

ឋិតនៅក្រោមបញ្ជារបស់ នាយកកងរាជអាវុធហត្ថ មាន :

- សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ
- កងរាជអាវុធហត្ថផ្ទៃប្រទេស

- កងរាជអាវុធហត្ថចល័ត
- តម្រួតយោធា

## មាត្រា ៩ ៖ សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ

សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ ត្រូវទទួលបន្ទុក ៖

- រៀបចំកម្មវិធីបង្រៀន
- ហ្វឹកហ្វឺនបុគ្គលិក
- ត្រួតពិនិត្យការហ្វឹកហ្វឺន
- រៀបរៀង និង ចងក្រងឯកសារសំរាប់បង្រៀន
- ធ្វើសំណើទៅនាយកដ្ឋានកងរាជអាវុធហត្ថ នូវសំភារៈជាចាំបាច់សំរាប់ដំណើរការសិក្សាអោយមានប្រសិទ្ធភាព ។

## មាត្រា ១០: កងរាជអាវុធហត្ថផ្ទៃប្រទេស

កងរាជអាវុធហត្ថផ្ទៃប្រទេសដែលដាក់អោយអនុវត្តការងារនៅពេញផ្ទៃព្រះរាជាណាចក្រកម្ពុជា រហូតទៅដល់ថ្នាក់ ឃុំ ត្រូវទទួលបន្ទុកបំពេញបេសកកម្មរបស់កងរាជអាវុធហត្ថដែលមានចែងនៅក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ។

សមត្ថកិច្ច នៃកងរាជអាវុធហត្ថផ្ទៃប្រទេសអនុវត្តទៅលើពលរដ្ឋស៊ីវិល និង យោធា ។

## មាត្រា ១១: កងរាជអាវុធហត្ថចល័ត

កងរាជអាវុធហត្ថចល័ត ជាកងកម្លាំងសំរាប់ប៉ាប់រង អោយមានគុណភាពខ្ពស់ និងប្រយុទ្ធប្រឆាំងនឹងក្រុមប្រដាប់អាវុធខុសច្បាប់ ។ កងរាជអាវុធហត្ថចល័តអនុវត្តការងារពេញផ្ទៃប្រទេស តាមការស្នើពីកងរាជអាវុធហត្ថផ្ទៃប្រទេស ឬ តាមសំបុត្រកំណែនពីអាជ្ញាធរមានសមត្ថកិច្ច ផ្នែករដ្ឋបាល ឬ តុលាការ ។ កងរាជអាវុធហត្ថចល័តត្រូវត្រៀមខ្លួនជានិច្ចសំរាប់បន្ថែមកម្លាំងក្នុងពេលខ្លីបំផុតទៅជួយកងឯកភាពនៃកងរាជអាវុធហត្ថផ្ទៃប្រទេស ។

## មាត្រា ១២: តម្រួតយោធា

តម្រួតយោធា គឺ ជាកងកម្លាំងមួយនៃកងរាជអាវុធហត្ថ ដែលមានភារកិច្ចចុះទៅធ្វើការផ្ទាល់ជាមួយនិងកងទ័ពទាំង ៣ ប្រភេទ នៃកងយោធពលខេមរភូមិន្ទ ។ តម្រួតយោធាបំពេញ

បេសកកម្មនេះ ក្រោមបញ្ជាអាជ្ញាធរ ដូចមានចែងក្នុងវគ្គ “ គ ” នៃមាត្រា ៤ នៃអនុក្រឹត្យនេះ ។

មាត្រា១៣: អធិការ ឬ នាយកកងអាវុធហត្ថអាចស្នើបង្កើតនូវអង្គភាពឯកទេសផ្សេងៗទៀត ដើម្បីប្រសិទ្ធភាពការងារក្នុងកាលៈទេសៈចាំបាច់ ។

មាត្រា១៤: ប្រគល់ជូនសហរដ្ឋមន្ត្រីការពារជាតិ និង នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ នូវនាទីកំណត់ភារកិច្ច ចំនួនជាក់ស្តែងនិងការស្នើតែងតាំង ក្នុងការរៀបចំស្ថាប័ន ដែលមានចែងខាងលើ ដោយមានការពិគ្រោះយោបល់ជាមួយសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា១៥: បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយអំពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា១៦: សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ និងគ្រប់ក្រសួងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង កុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
|---|---|
| ព្រះហស្ថលេខានិងត្រា | ហត្ថលេខានិងត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៤

## អនុក្រឹត្យលេខ ២៦ អនក្រ

## ស្តីពី និយត្តភាពសាមាសភាពនៃ

## ក្រសួងមហាផ្ទៃ ពីជំពូក ១១ មកជំពូក ១២

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះ